

# ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

តំបន់អាស៊ីអាគ្នេយ៍កំពុងប្រឈមមុខនឹងវិបត្តិនៃការប្រែប្រួលអាកាសធាតុដ៏ធ្ងន់ធ្ងរ ដែលកំពុងគម្រាមកំហែងដល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងតំបន់។ សមាជិកសភាដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា ប្រទេសរបស់ខ្លួនបានចាត់វិធានការត្រឹមត្រូវក្នុងការឆ្លើយតបនឹងស្ថានភាពគ្រោះថ្នាក់បន្ទាន់នៃអាកាសធាតុនេះ។ ឯកសារនេះមានគោលបំណងពន្យល់អំពីព័ត៌មាន និងវិធានការសំខាន់ៗ ដែលសមាជិកសភាក្នុងតំបន់អាស៊ីអាគ្នេយ៍អាចប្រើប្រាស់ដើម្បីធានាឲ្យមានការចាត់វិធានការត្រឹមត្រូវក្នុងការកាត់បន្ថយការប្រែប្រួលអាកាស។

## តើការកាត់បន្ថយការប្រែប្រួលអាកាសធាតុគឺជាអ្វី?

ការប្រែប្រួលអាកាសធាតុសំដៅដល់កំណើនសីតុណ្ហភាពពិភពលោក ដែលបណ្តាលមកពីការកើនឡើងនូវឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស។ មានវិធីពីរយ៉ាងដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ៖ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលសំដៅដល់សកម្មភាពនៃការកាត់បន្ថយការកើនឡើងនូវឧស្ម័នផ្ទះកញ្ចក់។ ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ដែលសំដៅដល់ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើសង្គម។

## តើកិច្ចព្រមព្រៀងទីក្រុងប៉ារីសគឺជាអ្វី?

មានជាង១៨០ប្រទេស បានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុដែលបានចូលជាធរមាន នៅខែវិច្ឆិកា ឆ្នាំ២០១៦។ ក្នុងនោះក៏រួមបញ្ចូលទាំងរដ្ឋជាសមាជិកអាស៊ានទាំងអស់ និងប្រទេសទីម័រខាងកើត។ គោលបំណងមួយនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីកម្រិតកំណើនសីតុណ្ហភាពពិភពលោកឲ្យនៅក្រោម ២អង្សាសេ លើកម្រិតសីតុណ្ហភាពនៅមុនពេលចាប់ផ្តើមមានបដិវត្តន៍ឧស្សាហកម្ម និងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីកម្រិតកំណើនសីតុណ្ហភាព ឲ្យនៅត្រឹម ១,៥អង្សាសេ លើកម្រិតសីតុណ្ហភាពនៅមុនពេលចាប់ផ្តើមមានបដិវត្តន៍ឧស្សាហកម្ម។

## តើរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិគឺជាអ្វី?

ដើម្បីសម្រេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសនេះ ប្រជាជាតិទាំងអស់ត្រូវរៀបចំផែនការសកម្មភាពអាកាសធាតុ ហៅថា “របាយការណ៍នៃការចូលរួមចំណែករបស់ជាតិ” ដាក់ជូនអង្គការសហប្រជាជាតិ នៅត្រឹមខែធ្នូ ឆ្នាំ២០២០។ របាយការណ៍នៃការចូលរួមចំណែករបស់ជាតិ ពន្យល់លម្អិតអំពីវិធីសាស្រ្តដែលប្រជាជាតិមានបំណងប្រើប្រាស់ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៃប្រជាជាតិនោះ ស្របតាមវត្ថុបំណងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ប្រទេសជាសមាជិកអាស៊ានទាំងអស់ ព្រមទាំងប្រទេសទីម័រខាងកើត បានដាក់របាយការណ៍នៃការចូលរួមចំណែករបស់ជាតិរបស់ខ្លួនជូនអង្គការសហប្រជាជាតិរួចហើយ។ របាយការណ៍នៃការចូលរួមចំណែករបស់ជាតិ ត្រូវបានត្រួតពិនិត្យរៀងរាល់៥ឆ្នាំ ដែលនឹងចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ២០២១ នៅឯសន្និសីទអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០២១ ឬសម័យប្រជុំលើកទី២៦ នៃសន្និសីទរដ្ឋភាគីរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (COP 26) នៅចក្រភពអង់គ្លេស។



## តើសន្និសីទអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០២១ ឬ សម័យប្រជុំលើកទី២៦ នៃសន្និសីទរដ្ឋភាគីរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (COP 26) គឺជាអ្វី?

កិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ២០១៥ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) នៅឯសន្និសីទរដ្ឋភាគី (COP)។ សន្និសីទរដ្ឋភាគីប្រព្រឹត្តទៅរៀងរាល់ឆ្នាំ។ សន្និសីទរដ្ឋភាគីនាឆ្នាំក្រោយនេះ គឺជាសន្និសីទអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០២១ ឬសម័យប្រជុំលើកទី២៦ នៃសន្និសីទរដ្ឋភាគីរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (COP 26) ហើយនឹងប្រព្រឹត្តទៅនៅទីក្រុង Glasgow ចក្រភពអង់គ្លេស នៅខែវិច្ឆិកា ឆ្នាំ២០២១ បន្ទាប់ពីសន្និសីទនេះត្រូវបានពន្យាពេលដោយសារជំងឺកូវីដ១៩។ សន្និសីទនេះគឺជាសន្និសីទរដ្ឋភាគីលើកដំបូង ដើម្បីត្រួតពិនិត្យផែនការសកម្មភាពអាកាសធាតុរបស់ប្រទេសនានា (ឬរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ)។

## តើរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៃអាស៊ានមានអ្វីជាបញ្ហា?

យោងតាមអង្គការសហប្រជាជាតិ របាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៃពិភពលោក មានលក្ខណៈខ្វះខាត និងមិនសមស្របដើម្បីសម្រេចគោលបំណងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក្នុងការកម្រិតកំណើនសីតុណ្ហភាពឲ្យនៅក្រោម ២អង្សាសេ។ ផ្ទុយទៅវិញ ពិភពលោកកំពុងស្ថិតនៅលើគន្លងឆ្ពោះទៅរកកំណើនសីតុណ្ហភាព ៣,២អង្សាសេ ដែលជាស្ថានភាពដ៏គ្រោះថ្នាក់សម្រាប់ប្រជាពលរដ្ឋនៃតំបន់អាស៊ីអាគ្នេយ៍។ របាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៃអាស៊ានទាំងអស់ត្រូវបានអ្នកវិទ្យាសាស្ត្របញ្ជាក់ថា “មានភាពខ្វះខាត” ដើម្បីសម្រេចបានតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដោយរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិរបស់ប្រទេសឥណ្ឌូនេស៊ី និងប្រទេសសិង្ហបុរី ត្រូវបានបញ្ជាក់ថា “មានភាពខ្វះខាតច្រើន”។

## តើរដ្ឋាភិបាលគួរធ្វើអ្វីខ្លះ?

ដោយសារតែរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៅមានភាពខ្វះខាតឆន្ទៈក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងដោយសារសេណារីយ៉ូដ៏គ្រោះថ្នាក់ដែលតំបន់អាស៊ីអាគ្នេយ៍កំពុងប្រឈម រដ្ឋាភិបាលនៃអាស៊ានចាំបាច់ត្រូវដាក់ជូនម្តងទៀតនូវរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិដែលត្រូវបានកែសម្រួលឲ្យប្រសើរឡើង ដោយមានវត្ថុបំណងពោរពេញដោយឆន្ទៈធំជាងមុន ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅមុនពេលសន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០២១ ឬសម័យប្រជុំលើកទី២៦ នៃសន្និសីទរដ្ឋភាគីរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (COP 26) គឺត្រឹមចុងឆ្នាំ២០២០។

# តើសមាជិកសភាអាចធ្វើអ្វីខ្លះ?

ជម្រុញឲ្យរដ្ឋាភិបាលរបស់អ្នកដាក់ជូនរបាយការណ៍ថ្មីនៃការចូលរួមចំណែករបស់ជាតិ (NDCs) ដែលត្រូវបានធ្វើការកែសម្រួលឲ្យប្រសើរឡើង ដោយមានឆន្ទៈធំជាងមុន នៅត្រឹមចុងឆ្នាំ២០២០។ បច្ចុប្បន្ន មានតែប្រទេសទីម័រខាងកើត ភូមា ឡាវ និងកម្ពុជាប៉ុណ្ណោះ បានប្តេជ្ញាថានឹងធ្វើការកែសម្រួលរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិរបស់ខ្លួនឲ្យប្រសើរឡើង។ រដ្ឋាភិបាលនៃអាស៊ានដទៃផ្សេងទៀតត្រូវយកគំរូតាមប្រទេសទីម័រខាងកើត ភូមា ឡាវ និងកម្ពុជា។ សូមមើលអនុសាសន៍ជាក់លាក់សម្រាប់បណ្តាប្រទេសទាំងនោះ។

ទាមទារឲ្យរដ្ឋាភិបាលបង្ហាញការទទួលខុសត្រូវ ដោយស្នើឲ្យរដ្ឋាភិបាលបញ្ជាក់នៅក្នុងសភា អំពីគោលនយោបាយរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងសេចក្តីសម្រេចក្នុងការមិនធ្វើការកែសម្រួលរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិរបស់ខ្លួនឲ្យប្រសើរឡើង បើទោះបីជាមានស្ថានភាពគ្រោះថ្នាក់នៃអាកាសធាតុក៏ដោយ។
ការពិភាក្សាដេញដោលអំពីថវិកា ក៏ជាឱកាសមួយផ្សេងទៀត ដើម្បីពិភាក្សាអំពីវិធានការក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុរបស់រដ្ឋាភិបាល។

បង្កើនការយល់ដឹងនិងលើកទឹកចិត្តឲ្យមានការពិភាក្សាក្នុងចំណោមប្រជាពលរដ្ឋម្ចាស់ឆ្នោតក្នុងមណ្ឌលបោះឆ្នោតរបស់អ្នក ព្រមទាំងអ្នកធ្វើគោលនយោបាយ អំពីសារៈសំខាន់នៃវិធានការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងព្រឹត្តិការណ៍សាធារណៈនានា។
ប្រើប្រាស់គណៈកម្មការសភា។ត្រូវធានាថា គណៈកម្មការដែលអ្នកជាសមាជិកនឹងធ្វើឲ្យបញ្ហាប្រែប្រួលអាកាសធាតុក្លាយជាបញ្ហាចម្បងផ្លូវការ ព្រមទាំងធ្វើការជាមួយអ្នកជំនាញ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃផ្សេងទៀត។ នៅក្នុងប្រទេសមួយចំនួន គណៈកម្មការជំនាញអាចស្នើសុំព័ត៌មាន និងធ្វើការសាកសួរអំពីការប្រតិបត្តិរបស់រដ្ឋាភិបាលក្នុងការសម្រេចតាមគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងស្នើសុំការឆ្លើយតបជាផ្លូវការ។

សិក្សាស្វែងយល់អំពីវត្ថុបំណងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងអនុសាសន៍របស់អ្នកវិទ្យាសាស្រ្ត សម្រាប់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់សម្រាប់ប្រទេសរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែម សូមមើលផ្នែកអនុសាសន៍ខាងក្រោម។ ពិភាក្សាជាមួយអ្នកវិទ្យាសាស្រ្តផ្នែកអាកាសធាតុ និងភាគីពាក់ព័ន្ធដទៃផ្សេងទៀត រួមទាំងសង្គមស៊ីវិលក្នុងតំបន់របស់អ្នកផងដែរ។

ជួបជាមួយប្រជាពលរដ្ឋម្ចាស់ឆ្នោតក្នុងមណ្ឌលបោះឆ្នោតរបស់អ្នក ហើយចាប់ផ្តើមដោះស្រាយទុក្ខកង្វល់របស់ពួកគេពាក់ព័ន្ធនឹងអាកាសធាតុ។ ឧទាហរណ៍ ពិភាក្សាជាមួយពួកគេអំពីវិធីក្នុងការធានាជីវភាពរស់នៅរបស់ពួកគេ ខណៈពេលដែលបរិស្ថានរស់នៅរបស់ពួកគេមានការប្រែប្រួល ដោយរួមបញ្ចូលទាំងអ្នកដែលមិនមានសិទ្ធិបោះឆ្នោតផងដែរ ដូចជា កុមារ និងជនចំណាកស្រុក។

អ្នកអាចលើកឡើងអំពីទុក្ខលំបាកទាំងនេះដើម្បីធ្វើការតស៊ូមតិទាមទារឲ្យមានភាពចាំបាច់ក្នុងការបង្កើនឆន្ទៈដោះស្រាយបញ្ហាអាកាសធាតុ និងធ្វើឲ្យប្រាកដថា វិធីសាស្រ្តដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនេះនឹងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតរបស់អ្នក។ សរសេរទៅកាន់ជនបង្គោលនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៃរដ្ឋាភិបាលរបស់អ្នក ដើម្បីស្វែករកព័ត៌មានស្តីពីរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៃប្រទេសរបស់អ្នក និងស្នើសុំធ្វើជាសមាជិកគណៈប្រតិភូតំណាងប្រទេសចូលរួមសន្និសីទអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០២១ ឬសម័យប្រជុំលើកទី២៦ នៃសន្និសីទរដ្ឋភាគីរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (COP 26) ដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០២១ ។ ធ្វើបែបនេះអាចធានាបាននូវការត្រួតពិនិត្យរបស់សភាកាន់តែខ្លាំងលើការចរចា និងដំណើរការត្រួតពិនិត្យរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ។

# ការធ្វើការជាមួយអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC)

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC) គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវបានអនុម័តក្នុងឆ្នាំ១៩៩២។ វត្ថុបំណងនៃអនុសញ្ញានេះ គឺ "ស្ថេរភាព និងការកសាងឡើងវិញនូវកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ដែលនឹងការពារមិនឲ្យសារធាតុបំពុល ឬកខ្វក់ដ៏គ្រោះថ្នាក់ជ្រាបចូលក្នុងប្រព័ន្ធអាកាសធាតុ"។ ប្រទេសនីមួយៗមានជនបង្គោលនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ម្នាក់ ដែលត្រូវបានចាត់តាំងដោយរដ្ឋាភិបាល។ កាតព្វកិច្ចរបស់ជនបង្គោល គឺដើម្បីទាក់ទងជាមួយអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងដើម្បីចែករំលែកព័ត៌មាននៅថ្នាក់ជាតិ។

សមាជិកសភាអាចភ្ជាប់ទំនាក់ទំនងទៅកាន់ជនបង្គោលនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៃប្រទេសរបស់ខ្លួន ដើម្បីស្វែងយល់បន្ថែមអំពីស្ថានភាពនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៃប្រទេសរបស់ខ្លួន និងតស៊ូមតិដើម្បីជម្រុញឲ្យប្រទេសរបស់ខ្លួនមានឆន្ទៈកាន់តែខ្លាំងក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

## ប្រទេសកម្ពុជា

**ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន (១)**
**លោក ម៉ៅ ហាក់ នាយក, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (២)**

☏ (855-23) 21-3908 / 4-27894 (1)
✉ moe-cabinet@camnet.com.kh (1)
✉ cceap@online.com.kh(2)

## ប្រទេសឥណ្ឌូនេស៊ី

**លោក** Ruandha Agung Sugardiman **អគ្គនាយក, ក្រសួងបរិស្ថាន និងរុក្ខាប្រមាញ់**

☏(62-21) 5730 144
✉ nfpcc.indonesia@gmail.com

## ប្រទេសម៉ាឡេស៊ី

**លោក** Mr. Jaya Singam Rajoo **អនុរដ្ឋលេខាធិការជាន់ខ្ពស់ (១)**
**លោក** Md Yusup Yusmazy **អនុរដ្ឋមន្ត្រីជាន់ខ្ពស់ (២)**
**ក្រសួងថាមពល វិទ្យាសាស្ត្រ បច្ចេកវិទ្យា បរិស្ថាន និងប្រែប្រួលអាកាសធាតុ**

☏ (60-3) 8885-8690 (1)
✉ jayasingam@mestecc.gov.my (1)
☏(60-3)8885-8675 (2)
✉ yusmazy@mestecc.gov.my (2)

## ប្រទេសភូមា

**លោក** Hla Maung Thein **អគ្គនាយកនៃនាយកដ្ឋានអភិរក្សបរិស្ថាន, ក្រសួងធនធានធម្មជាតិ និងអភិរក្សបរិស្ថាន**

☏ (95-67) 431343
✉ dg.ecd@moecaf.gov.mm
✉ hlamaungthein.env@gmail.com

## ប្រទេសហ្វីលីពីន

**ឯកឧត្តម** Emmanuel De Guzman **រដ្ឋមន្ត្រី និងជាអនុប្រធានគណៈកម្មការប្រែប្រួលអាកាស (១)**
**អ្នកស្រី** Noralyn Jubaira-Baja **អនុរដ្ឋមន្ត្រីនៃគណៈកម្មការប្រែប្រួលអាកាស** (២)

☏ (63-2) 735-6201 / 564-1451 to 80 (1)
✉ emmanuel.m.deguzman@gmail.com
✉ osec.ccc.ph@gmail.com (1)
✉ unio.div2@dfa.gov.ph (2)

## ប្រទេសសិង្ហបុរី

**លោក** Cheah Sin Liang **អ្នកសម្របសម្រួលដឹកនាំការចរចាអាកាសធាតុ, នាយករង, ក្រុមយុទ្ធសាស្ត្រ, ការិយាល័យនាយករដ្ឋមន្ត្រី**

☏ (65) 6354 9221, (65) 6354 9218
✉ nccs_international@pmo.gov.sg
✉ cheah_sin_liang@pmo.gov.sg

## ប្រទេសទីម័រខាងកើត

**លោក** Adao Soares Barbosa **ជនបង្គោលថ្នាក់ជាតិនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ** (UNFCCC), **រដ្ឋលេខាធិការដ្ឋានបរិស្ថាន និងដាំដើមឈើឡើងវិញ**

☏ (670) 333-1118
✉ adaosoaresb@yahoo.com

## ប្រទេសថៃ

**អ្នកស្រី** Natthanich Asvapoositkul **នាយកផ្នែកសម្របសម្រួល និងគ្រប់គ្រងការប្រែប្រួលអាកាសធាតុ, ក្រសួងធនធានធម្មជាតិ និងបរិស្ថាន**

☏ (66-2) 265 6690
✉ natthan.asv@gmail.com
✉ unfccc.thailand.focalpoint@gmail.com

# អនុសាសន៍ដើម្បីធ្វើឲ្យប្រសើរឡើងនូវផែនការសកម្មភាពអាកាសធាតុ

តារាងខាងក្រោមសង្ខេបអំពីអនុសាសន៍សំខាន់ៗរបស់អ្នកវិទ្យាសាស្ត្រ សម្រាប់របាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៃបណ្ដាប្រទេសជាសមាជិកអាស៊ាន ដើម្បីឲ្យស្របតាមគោលបំណងនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ សមាជិកសភាអាចធានាថា អនុសាសន៍ទាំងនេះត្រូវបានទទួលយក និងអនុវត្តដោយរដ្ឋាភិបាល។

## ប្រទេសឥណ្ឌូនេស៊ី

**វត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ***

ការកាត់បន្ថយដោយមានល័ក្ខខ័ណ្ឌនូវការបំភាយឧស្ម័នផ្ទះកញ្ចក់រហូតដល់៤១% នៃសេណារីយ៉ូនៃការបន្តធ្វើសកម្មភាពដដែលៗរបស់មនុស្ស ត្រឹមឆ្នាំ២០៣០

**ការវាយតម្លៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ**

**+៤ អង្សា****

**✗ មានភាពខ្វះខាតច្រើន**

**✓លើកឡើងអំពីសិទ្ធិមនុស្ស**

**✗ គ្មានការប្ដេជ្ញាចិត្តក្នុងការបង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ត្រឹមឆ្នាំ២០២០**

**អនុសាសន៍សម្រាប់វឌ្ឍនភាព**

- បង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងវត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ
- បញ្ឈប់ការវិនិយោគ និងការប្រើប្រាស់ធ្យូងថ្ម ត្រឹមឆ្នាំ២០៤០
- បញ្ឈប់ការផ្ដល់ឧបត្ថម្ភធនឥន្ធនៈផូស៊ីល
- ធានាថាប្រទេសឥណ្ឌូនេស៊ីទទួលបានថាមពលដែលអាចកកើតថ្មីបាននូវបរិមាណតាមគោលដៅកំណត់របស់ខ្លួន
- ដោះស្រាយបញ្ហានៃការកាប់បំផ្លាញព្រៃឈើ អគ្គីភ័យ និងអ័ព្ទ
- គ្រប់គ្រងការពង្រីកវិស័យប្រេងដូង ព្រមទាំងឥន្ធនៈជីវសាស្ត្រ
- កំណត់រយៈពេលដើម្បីសម្រេចបាននូវការបំភាយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតសូន្យ តាមរយៈការធ្វើច្បាប់
- ធ្វើឲ្យលំហូរហិរញ្ញវត្ថុទាំងអស់ស៊ីគ្នាយ៉ាងពេញទំហឹងជាមួយនឹងគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស

## ប្រទេសម៉ាឡេស៊ី

**វត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ***

កាត់បន្ថយអាំងតង់ស៊ីតេបំភាយឧស្ម័នផ្ទះកញ្ចក់ ៤៥% នៃផលិតផលក្នុងស្រុកសរុប (GDP) របស់ខ្លួន ត្រឹមឆ្នាំ២០៣០ ពាក់ព័ន្ធនឹងអាំងតង់ស៊ីតេបំភាយឧស្ម័ននៃផលិតផលក្នុងស្រុកសរុប (GDP) របស់ខ្លួន ក្នុងឆ្នាំ២០០៥

**ការវាយតម្លៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ**

**✗ មានភាពខ្វះខាត**

**✗ មិនមានការលើកឡើងអំពីសិទ្ធិមនុស្ស**

**✗ គ្មានការប្ដេជ្ញាចិត្តក្នុងការបង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ត្រឹមឆ្នាំ២០២០**

**អនុសាសន៍សម្រាប់វឌ្ឍនភាព**

- បង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងវត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ
- ជម្រុញការអភិវឌ្ឍន៍ការដឹកជញ្ជូនសាធារណៈ
- ធ្វើឲ្យលំហូរហិរញ្ញវត្ថុទាំងអស់ស៊ីគ្នាយ៉ាងពេញទំហឹងជាមួយនឹងគោលដៅកិច្ចព្រមព្រៀងទីក្រុងប៉ារីស
- បញ្ឈប់ការវិនិយោគ និងការប្រើប្រាស់ធ្យូងថ្ម ត្រឹមឆ្នាំ២០៤០
- បញ្ឈប់ការផ្ដល់ឧបត្ថម្ភធនឥន្ធនៈផូស៊ីល
- គ្រប់គ្រងការពង្រីកវិស័យប្រេងដូង ព្រមទាំងឥន្ធនៈជីវសាស្ត្រ និងបង្កើនស្តង់ដាទទួលស្គាល់គុណភាព
- កំណត់រយៈពេលដើម្បីសម្រេចបាននូវការបំភាយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតសូន្យ តាមរយៈការធ្វើច្បាប់
- ប្ដេជ្ញាចិត្តក្នុងការការពារ លើកកម្ពស់ និងគោរពសិទ្ធិមនុស្ស នៅក្នុងវិធានការអាកាសធាតុ

## ប្រទេសហ្វីលីពីន

**វត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ***

កាត់បន្ថយការបំភាយឧស្ម័នប្រហែល៧០% ពាក់ព័ន្ធនឹងសេណារីយ៉ូនៃការបន្តធ្វើសកម្មភាពដដែលៗរបស់មនុស្ស ត្រឹមឆ្នាំ២០៣០

**ការវាយតម្លៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ**

**+២ អង្សា****

**✓លើកឡើងអំពីសិទ្ធិមនុស្ស**

**✗ គោលនយោបាយមិននៅលើគន្លងឆ្ពោះទៅសម្រេចវត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ**

**✗ គ្មានការប្ដេជ្ញាចិត្តក្នុងការបង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ត្រឹមឆ្នាំ២០២០**

**អនុសាសន៍សម្រាប់វឌ្ឍនភាព**

- បង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងវត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ
- ដាក់ជូនរបាយការណ៍ថ្មីនៃការចូលរួមចំណែករបស់ជាតិ ដែលបញ្ជាក់អំពីតើអ្វីជាសេណារីយ៉ូនៃការបន្តធ្វើសកម្មភាពដដែលៗរបស់មនុស្ស
- គណនាបរិមាណនៃឧស្ម័នភាយចេញពីការប្រើប្រាស់ដីនាពេលអនាគត
- កំណត់រយៈពេលដើម្បីសម្រេចបាននូវការបំភាយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតសូន្យ តាមរយៈការធ្វើច្បាប់
- បញ្ឈប់ការផ្ដល់ឧបត្ថម្ភធនឥន្ធនៈផូស៊ីល
- ធ្វើឲ្យលំហូរហិរញ្ញវត្ថុទាំងអស់ស៊ីគ្នាយ៉ាងពេញទំហឹងជាមួយនឹងគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស
- បញ្ឈប់ការវិនិយោគ និងការប្រើប្រាស់ធ្យូងថ្ម ត្រឹមឆ្នាំ២០៤០

## ប្រទេសសិង្ហបុរី

### វត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ*

កាត់បន្ថយអាំងតង់ស៊ីតេបំភាយឧស្ម័នរបស់ខ្លួន ត្រឹម ៣៦% ចាប់ពីកម្រិតឆ្នាំ២០០៥ ត្រឹមឆ្នាំ២០៣០ និងរក្សាឲ្យបាននូវស្ថេរភាពនៃការបំភាយឧស្ម័ននៅកម្រិតនេះ ក្នុងគោលបំណងដើម្បីសម្រេចបាននូវលទ្ធផលប្រសើរបំផុត នៅឆ្នាំ២០៣០

### ការវាយតម្លៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ

**+៤ អង្សា****

**✗ មានភាពខ្វះខាតច្រើន**

**✗ មិនមានការលើកឡើងអំពីសិទ្ធិមនុស្ស**

**✗ គ្មានការប្តេជ្ញាចិត្តក្នុងការបង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ត្រឹមឆ្នាំ២០២០**

### អនុសាសន៍សម្រាប់វឌ្ឍនភាព

- បង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងវត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ
- ដោះស្រាយបញ្ហាពឹងផ្អែកលើឧស្ម័ន (ល្បាយថាមពលដែលត្រូវបានបង្រួមប្រហែលនឹងបណ្តាលឲ្យមានការពឹងផ្អែកលើឥន្ធនៈផូស៊ីល)
- ដោះស្រាយបញ្ហាកម្រិតចាប់ផ្តើមទាបនៃពន្ធលើប្រេងឥន្ធនៈ
- កំណត់រយៈពេលដើម្បីសម្រេចបាននូវការបំភាយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតសូន្យ តាមរយៈការធ្វើច្បាប់
- បញ្ឈប់ការផ្តល់ឧបត្ថម្ភធនឥន្ធនៈផូស៊ីល
- ធ្វើឲ្យលំហូរហិរញ្ញវត្ថុទាំងអស់ស៊ីគ្នាយ៉ាងពេញទំហឹងជាមួយនឹងគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស
- បញ្ឈប់ការវិនិយោគ (ទាំងនៅក្រៅប្រទេស) និងការប្រើប្រាស់ធ្យូងថ្ម ត្រឹមឆ្នាំ២០៤០
- ប្តេជ្ញាចិត្តក្នុងការការពារ លើកកម្ពស់ និងគោរពសិទ្ធិមនុស្ស នៅក្នុងវិធានការអាកាសធាតុ

## ប្រទេសថៃ

### វត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ*

កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន ត្រឹម ២៥% ពីកម្រិតដែលត្រូវបានព្យាករណ៍ទុកនៃការបន្តធ្វើសកម្មភាពដដែលៗរបស់មនុស្ស នៅត្រឹមឆ្នាំ២០៣០។

### ការវាយតម្លៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ

**✗ មានភាពខ្វះខាត**

**✗ មិនមានការលើកឡើងអំពីសិទ្ធិមនុស្ស**

**✗ គ្មានការប្តេជ្ញាចិត្តក្នុងការបង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ត្រឹមឆ្នាំ២០២០**

### អនុសាសន៍សម្រាប់វឌ្ឍនភាព

- បង្កើនឆន្ទៈដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងវត្ថុបំណងនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ
- ពង្រីកប្រព័ន្ធគមនាគមន៍ស្អាត
- កំណត់រយៈពេលដើម្បីសម្រេចបាននូវការបំភាយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតសូន្យ តាមរយៈការធ្វើច្បាប់
- បញ្ឈប់ការផ្តល់ឧបត្ថម្ភធនឥន្ធនៈផូស៊ីល
- ធ្វើឲ្យលំហូរហិរញ្ញវត្ថុទាំងអស់ស៊ីគ្នាយ៉ាងពេញទំហឹងជាមួយនឹងគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស
- បញ្ឈប់ការវិនិយោគ (ទាំងនៅក្រៅប្រទេស) និងការប្រើប្រាស់ធ្យូងថ្ម ត្រឹមឆ្នាំ២០៤០
- ប្តេជ្ញាចិត្តក្នុងការការពារ លើកកម្ពស់ និងគោរពសិទ្ធិមនុស្ស នៅក្នុងវិធានការអាកាសធាតុ

*នេះសំដៅដល់គោលដៅកំណត់ចំពោះការបំភាយឧស្ម័នដោយមានល័ក្ខខ័ណ្ឌនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ។ មិនដូចគ្នានឹងគោលដៅកំណត់ចំពោះការបំភាយឧស្ម័នដោយគ្មានល័ក្ខខ័ណ្ឌនៃរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិនោះទេ គោលដៅកំណត់ចំពោះការបំភាយឧស្ម័នដោយមានល័ក្ខខ័ណ្ឌអាស្រ័យទៅលើការផ្តល់មូលនិធិសមរម្យពីសហគមន៍ពិភពលោក ដើម្បីចាត់វិធានការ។
**នេះមានន័យថា ប្រសិនបើប្រទេសទាំងអស់មានកម្រិតឆន្ទៈដូចគ្នា បើប្រៀបធៀបទៅនឹងកម្រិតនៃការបំភាយឧស្ម័នរបស់ប្រទេសទាំងអស់នោះ សីតុណ្ហភាពនៃភពផែនដីរបស់យើងនឹងកើនត្រឹម ៤ (ឬ ២ សម្រាប់ប្រទេសហ្វីលីពីន) អង្សាសេ ត្រឹមឆ្នាំ២១០០។
*Data is According to the The truth behind the climate pledges report, UNFCCC NDC registry, Climate scorecard, Climate Action Tracker, Climate Watch 2020 NDC Tracker, NDC Explorer, Climate Analytics report, STOTEN 650 (2) 1858-1871, accessed December 2019.*

## សម្រាប់ព័ត៌មានបន្ថែម៖

- Climate Action Tracker
- The Truth Behind the Climate Pledges, report
- United Nations Emissions Gap report 2019
- UNFCCC NDC registry
- Climate Watch 2020 NDC Tracker

ប្រសិនបើអ្នកចាប់អារម្មណ៍ចង់ទទួលបានព័ត៌មានបន្ថែមទៀត ឬចូលរួមជួយដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុទាំងនេះនៅក្នុងប្រទេស និងសភារបស់អ្នក សូមទំនាក់ទំនងអ្នកស្រី *Cannelle Gueguen-Teil* តាមរយៈអាសយដ្ឋានអ៊ីម៉ែល *cannelle@aseanmp.org*

APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS
www.aseanmp.org | twitter / facebook / instagram: @aseanmp
AUGUST 2020
FRIEDRICH EBERT STIFTUNG